# ការធ្វើតេស្តស្រាវជ្រាវរក មហារីកមាត់ស្បូន

ការធ្វើតេស្តស្រាវជ្រាវរកមហារីកមាត់ស្បូនអាចរកឃើញសញ្ញានៃការប្រែប្រួលកោសិកាមាត់ស្បូន។ ដំណើរការធ្វើតេស្តស្រាវជ្រាវរកមហារីកមាត់ស្បូនមានភាពសាមញ្ញនិងឆាប់រហ័ស។ អ្នកគ្រាន់តែដេកនៅលើគ្រែពិនិត្យ ហើយអ្នកផ្តល់សេវាដាក់បញ្ចូលសម្ភារៈសម្រាប់ពិនិត្យមាត់ស្បូន(ចំពុះទា) បង្ហើបទ្វារមាសដើម្បីងាយស្រួលក្នុងការពិនិត្យមាត់ស្បូនឱ្យបានច្បាស់។ អ្នកផ្តល់សេវាធ្វើការពិនិត្យមាត់ស្បូនមិនមែនគ្រាន់តែធ្វើការលាងសម្អាតនោះទេ។

នៅប្រទេសកម្ពុជាក្នុងពេលបច្ចុប្បន្ននេះការធ្វើតេស្តស្រាវជ្រាវរកមហារីកមាត់ស្បូនអាចធ្វើបានតាមរយៈ:

- HPV តេស្ត :
  អ្នកផ្តល់សេវាពិនិត្យមាត់ស្បូន និងគៀរយកកោសិកាពីមាត់ស្បូន យកទៅពិនិត្យដោយធ្វើតេស្ត HPV ។

- VIA :
  អ្នកផ្តល់សេវាពិនិត្យមាត់ស្បូនដោយប្រើទឹកថ្នាំបំពាក់ពណ៌ដើម្បីរកមើលភាពមិនធម្មតា នៃកោសិកាមាត់ស្បូន (កោសិកាមាត់ស្បូនមានការប្រែពណ៌) ។

- Pap smear (ការពិនិត្យគំនៀរមាត់ស្បូន) :
  អ្នកផ្តល់សេវាពិនិត្យមាត់ស្បូន និងគៀរយកកោសិកាបន្តិចពីមាត់ស្បូនយកទៅពិនិត្យដោយមីក្រូទស្សន៍។ ដំណើរការនេះត្រូវរងចាំលទ្ធផលពី១០ទៅ២០ថ្ងៃ។



## ការចាក់ថ្នាំបង្ការវីរុស អេច ភី វី

ការចាក់ថ្នាំបង្ការត្រូវធ្វើនៅពេលដែលស្ត្រីមិនធ្លាប់មានការរួមភេទ ឬមិនទាន់មានឆ្លងវីរុស អេច ភី វី ទើបមានប្រសិទ្ធភាពខ្ពស់។ ថ្នាំបង្ការវីរុស អេច ភី វី មិនអាចប្រឆាំងនឹងវីរុសអេច ភី វីដែលបង្កគ្រោះថ្នាក់ខ្ពស់បានគ្រប់ប្រភេទនោះទេ។ នេះជាហេតុផលមួយ ទោះបីជាស្ត្រីបានចាក់ថ្នាំបង្ការរួចហើយក៏ដោយ ក៏នៅតែចាំបាច់ត្រូវទៅពិនិត្យស្រាវជ្រាវរកមហារីកមាត់ស្បូនឱ្យបានទៀងទាត់ទៀតដែរ។

## ឯកសារយោង


Protocol for Prevention and Management for Cervical Pre-cancer and Cancer (SCGO, 2016 May)

Cervical Cancer Scope of the Problem in Cambodia (WHO Cancer Country Profile, 2014)

WHO guidance note "Comprehensive cervical cancer prevention and control: a healthier future for girls and women"

ACOG: The American College of Obstetricians and Gynecologists
http://www.acog.org/


## មន្ទីរពេទ្យដែលមានផ្តល់សេវាពិនិត្យស្រាវជ្រាវរកមហារីកមាត់ស្បូនមាននៅ:

**មជ្ឈមណ្ឌលជាតិគាំពារមាតានិងទារក**
**មន្ទីរពេទ្យមិត្តភាពខ្មែរសូវៀត**
**មន្ទីរពេទ្យកាល់ម៉ែត**

ក្រសួងសុខាភិបាល
Ministry of Health

SCGO: Cambodian Society of Gynecology and Obstetrics

JSOG: Japan Society of Obstetrics and Gynecology

NCGM: National Center for Global Health and Medicine

JICA: Japan International Cooperation Agency

ព័ត៌មានរបស់សមាគមសម្ភព និងរោគស្ត្រីវិទ្យាកម្ពុជា
គេហទំព័រ: www.scgo-kh.com


ផលិតដោយ SCGO
ឧបត្ថម្ភដោយ JSOG, NCGM, and JICA

បោះពុម្ពលើកទី២ ឆ្នាំ២០១៨


© រក្សាសិទ្ធិគ្រប់យ៉ាង


# នាំគ្នាទៅ

## ធ្វើតេស្តស្រាវជ្រាវរកមហារីកមាត់ស្បូន ដើម្បីសុខភាពរបស់យើង

### អំពីមហារីកមាត់ស្បូន



គ្រប់ស្ត្រីដែលធ្លាប់មានការរួមភេទអាចប្រឈមនឹងមហារីកមាត់ស្បូន។

ពីដំបូងមហារីកមាត់ស្បូនសំងំយ៉ាងស្ងៀមស្ងាត់មុននឹងដល់ពេលរាលដាល។ដូចនេះមិនមានអ្នកណាម្នាក់ដឹងខ្លួនជាមុនថានឹងមានមហារីកមាត់ស្បូនទេ។

គ្រប់ស្ត្រីដែលធ្លាប់មានការរួមភេទដំបូងលើសពី២ឆ្នាំ ពិសេសមានអាយុចាប់ពី២៥ឆ្នាំឡើង គប្បីទៅធ្វើតេស្តស្រាវជ្រាវរកមហារីកមាត់ស្បូនឱ្យបានទៀងទាត់រៀងរាល់ពីរឆ្នាំម្តង។

# អំពី មហារីកមាត់ស្បូន

មហារីកមាត់ស្បូន គឺជាជំងឺម៉្យាងរបស់ស្ត្រី។ ជំងឺនេះកើតមាននៅលើមាត់ស្បូនដែលស្ថិតនៅផ្នែកខាងក្រោមស្បូននៅក្នុងទ្វារមាស។

នៅប្រទេសកម្ពុជា ជារៀងរាល់ឆ្នាំមានស្ត្រីជាច្រើននាក់បានស្លាប់ ដោយសារមហារីកមាត់ស្បូន។




## រោគសញ្ញា នៃមហារីកមាត់ស្បូន

ស្ត្រីដែលមានមហារីកមាត់ស្បូនអាចមានរោគសញ្ញាណាមួយដូចជា ធ្លាក់សខុសធម្មតា ធ្លាក់ឈាមនៅចន្លោះវដ្តឈាមរដូវ ធ្លាក់ឈាមក្រោយវ័យអស់រដូវ មានធ្លាក់ឈាមឬឈឺពេលរួមភេទ។

# មូលហេតុឱ្យមាន មហារីកមាត់ស្បូន

មហារីកមាត់ស្បូនបណ្ដាលមកពីវីរុសឈ្មោះ អេច ភី វី ។ វីរុសជាសរីរាង្គដ៏តូចបំផុតមិនអាចមើលឃើញដោយភ្នែកទទេបានទេ ។វីរុស អេច ភី វី ខ្លះ បង្កឱ្យកើតឫសនៅលើរាងកាយ ឯ វីរុស អេច ភី វី ខ្លះទៀតបង្កទៅជាមហារីកមាត់ស្បូន គឺជាប្រភេទ អេច ភី វី ដែលបង្កគ្រោះថ្នាក់ខ្ពស់។

មហារីកមាត់ស្បូនបណ្ដាលមកពីវីរុសឈ្មោះ អេច ភី វី (HPV)




## តើស្ត្រីឆ្លងវីរុស អេច ភី វី ប្រភេទដែលអាចបណ្ដាលឱ្យកើតមហារីកមាត់ស្បូន (វីរុស អេច ភី វី បង្កគ្រោះថ្នាក់ខ្ពស់) យ៉ាងដូចម្ដេច?

ស្ត្រីឆ្លងវីរុស អេច ភី វី ដែលអាចបណ្ដាលឱ្យកើតមហារីកមាត់ស្បូនបានតាមរយៈការរួមភេទ។ ស្ទើរតែគ្រប់អ្នកដែលសកម្មក្នុងការរួមភេទ អាចប្រឈមនឹងការឆ្លងវីរុស អេច ភី វី បាន នៅក្នុងដំណាក់កាលណាមួយនៃជីវិតរបស់ពួកគេ។

# តើមានអ្វីកើតឡើងប្រសិនបើ

## វីរុស អេច ភី វី ដែលបង្កគ្រោះថ្នាក់ខ្ពស់ស្ថិតនៅក្នុងមាត់ស្បូនរបស់អ្នក?




## តើមានអ្វីកើតឡើងប្រសិនបើវីរុស អេច ភី វី ស្ថិតនៅមាត់ស្បូន?

ដំបូងវីរុស អេច ភី វី សំងំយ៉ាងស្ងៀមស្ងាត់មួយរយៈពេលយូរ មុននឹងមាត់ស្បូនមានការប្រែប្រួល។ ប្រមាណ១០ឆ្នាំក្រោយទើបក្លាយជាមហារីកមាត់ស្បូន។ មិនមានអ្នកណាម្នាក់ដឹងខ្លួនជាមុនថានឹងកើតមហារីកនោះទេ។ ក្នុងអំឡុងពេល វីរុស អេច ភី វី បង្ករោគរហូតដល់ត្រៀមជាមហារីក មិនមានបង្ហាញជាសញ្ញាណាមួយឡើយ។

## តើត្រូវធ្វើដូចម្ដេចដើម្បីជៀសវាងមហារីកមាត់ស្បូន?

- ✓ ការចាប់ចាក់ថ្នាំបង្ការ ៖ ការផ្ដល់ថ្នាំបង្ការនឹងមានប្រសិទ្ធភាពខ្ពស់ប្រសិនបើគេផ្ដល់ឱ្យស្ត្រីតាំងពីនៅវ័យក្មេងមុនពេលមានការរួមភេទ
- ✓ មានដៃគូរួមភេទតែមួយ
- ✓ ប្រើស្រោមអនាម័យរាល់ពេលរួមភេទ
- ✓ ធ្វើតេស្តស្រាវជ្រាវរកមហារីកមាត់ស្បូនឱ្យបានទៀងទាត់តាមការណាត់ជួបដើម្បីឆាប់រកឃើញនូវភាពប្រែប្រួលនៃមាត់ស្បូនឱ្យបានទាន់ពេល